អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែង បីងហ្គូសំឡេង**

**ភាសាខ្មែរ (ការប្រើពាក្យសម្ដីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង)៖** និមិត្តសញ្ញាតំណាងឱ្យមនុស្ស សត្វ ឬវត្ថុនានា

**(ការស្គាល់តួអក្សរ)**៖ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង

**គោលបំណង** ៖**ភាសាខ្មែរ** ៖ ប្រាប់ពីឈ្មោះសត្វ មនុស្ស វត្ថុឱ្យបានចំនួន ៤ តាមរយៈការធ្វើកាយវិការ ចលនាត្រាប់តាមនិមិត្តសញ្ញា។ សម្ដែងនូវអារម្មណ៍សប្បាយរីករាយក្នុងការបង្ហាញ និងប្រាប់ឈ្មោះមនុស្ស សត្វ វត្ថុដែលបានឃើញ។

៖ ស្ដាប់ និងបែងចែកសូរសំឡេងទូទៅ

៖សំឡេងសត្វសំឡេងមនុស្ស និងដឹងពីប្រភពសំឡេង…

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ បោះពុម្ពក្រដាសបីងហ្គូ និងអ៊ុតវាឱ្យបានស្អាត ប្រអប់សម្លេងដែលទាក់ទងនឹងរូបភាពទាំងអស់។

**កម្រិតសិក្សា** ៖ ទាប មធ្យម និងខ្ពស់

**ការរៀបចំ** ៖ ត្រៀមជាមួយនឹង ក្រដាសបីងហ្គូសម្លេងតាមរូបភាពនៅក្នុងកាតបីងហ្គូរនោះ និងសម្ភារសម្រាប់រាប់ឬសម្គាល់ឱ្យបានគ្រប់គ្រាន់

**សេក្តីណែនាំ៖**

1. ពិភាក្សាជាមួយក្មេងៗពីអ្វីដែលពួកគេគិតនិងឱ្យក្មេងៗធ្វើការសម្ដែងធ្វើមើលមិនឃើញទាំងអស់គ្នា។
2. ល្បែងនេះអាចទាំងអស់គ្នាតែម្ដង ព្រោះវាមានភាពងាយស្រួលជាងលេងជាក្រុម ។
3. ចែកក្រដាសបីងហ្គូធំ និងសម្ភារសម្រាប់សម្គាល់ទៅក្មេងៗឱ្យបានគ្រប់គ្រាន់
   - ☐ បញ្ជាក់៖ រូបភាពក្នុងក្រដាសបីងហ្គូ និងកាតតូចនោះជារូបអ្វីក៏បានដែរដូចជា៖ រូបសត្វ រូបសម្ភារតន្ត្រី រូបសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ជាដើម…។ តែត្រូវមានរូបភាពដូចគ្នា និងត្រូវគ្នា។

4. និយាយពីរូបភាពទាំងអស់ ដើម្បីឱ្យក្មេងៗបានស្គាល់ និងយល់ឱ្យច្បាស់ពីឈ្មោះ និងសម្លេងរបស់វា។
5. ប្រាប់ពួកគេទាំងអស់គ្នាថា ថ្ងៃនេះយើងលេងល្បែងប៊ីងហ្គូសម្លេង
   - ➔ ចែកក្រដាសប៊ីងហ្គូធំតាមចំនួននីមួយៗ សម្ភារសម្គាល់
   - ➔ ឱ្យក្មេងៗអង្គុយចុះទាំងអស់គ្នា និងត្រៀមដោយដាក់ក្រដាសប៊ីងហ្គូរនៅចំពីមុខ និងសម្ភារសម្គាល់ដូចគ្នា។
   - ➔ គ្រូធ្វើសម្លេង ឬចាក់សម្លេងតាមសត្វនីមួយៗឱ្យក្មេងបានដឹងជាមុនសិន (ប្រសិនបើគាត់មិនសូវបានស្គាល់សត្វទាំងនោះច្បាស់)។
   - ➔ ចាប់ផ្តើមលេងតែម្តង ដោយគ្រូចាប់រូបភាពមួយពីកាតរូបភាពតូច និងចាក់សម្លេងតាមរូបភាពដែលគ្រូចាប់បាន។
   - ➔ ក្មេងណាដែលមានរូបភាពដូចជាគ្រូបានចាក់សម្លេងនោះនៅក្នុងក្រដាសប៊ីងហ្គូរបស់ពួកគេ ពួកគេប្រើសម្ភារសម្គាល់មួយនៅលើក្រដាសប៊ីងហ្គូរបស់គេនោះ ។
   - ➔ ក្មេងណាដែលគ្មានសត្វដែលគ្រូចាក់សម្លេងដូចទេ មិនចាំបាច់ដាក់ទេ
   - ➔ ធ្វើបែបនេះរហូត ដល់ក្មេងណាដែលដាក់ពេញក្រដាសប៊ីងហ្គូរបស់ពួកគេមុន គេត្រូវស្រែកខ្លាំងៗថា ‹‹ប៊ីងហ្គូ›› បន្ទាប់មក គឺក្លាយជាអ្នកឈ្នះទី១
   - ➔ បន្ទាប់មកលេងបន្តដើម្បីរកអ្នកឈ្នះទី២ ទី៣ ទី ៤ គឺជាការស្រេច។
6. បើមានពេលឱ្យក្មេងផ្លាស់ប្តូរក្រដាសប៊ីងហ្គូគ្នានិងចាប់ផ្តើមលេងម្តងទៀតជាការស្រេច។

**ការប្រែប្រួល៖**

- ល្បែងនេះអ្នកអាចលេងដោយចែកក្មេងៗទៅជាក្រុមៗក៏បានដែរ ប្រសិនបើអ្នកមានពេល។
- យើងអាចលេងជាប្រភេទសម្ភារផ្សេងៗដែលយើងអាចមានសម្លេងដូចក៏បានដែរ តាមការច្នៃប្រឌិតរបស់អ្នក។